# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៤៧ សសរ

## សេចក្ដីសម្រេច
### ស្ដីពី
### ការបង្កើតក្រុមការងារសំរាប់ពិភាក្សាជាមួយតំណាង ស្នងការដ្ឋានជាន់ខ្ពស់របស់សហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួន នៅកម្ពុជា

---

### រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល កម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើ ច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- សេចក្ដីសំរេច លេខ ២៦ សសរ ចុះថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០០៤ ស្ដីពីការផ្ទេរសិទ្ធិការងាររបស់រាជរដ្ឋាភិបាល
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

### សំរេច

ប្រការ ១ : ត្រូវបានបង្កើតក្រុមការងារសំរាប់ពិភាក្សាជាមួយតំណាងស្នងការដ្ឋានជាន់ខ្ពស់របស់សហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួន នៅកម្ពុជា ដែលមានសមាសភាពដូចខាងក្រោមនេះ ៖

| | | |
|---|---|---|
| - ឯកឧត្ដម ឡុង វិសាលោ | អនុរដ្ឋលេខាធិការ ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ | ប្រធាន |
| - ឯកឧត្ដម ឱម យិនទៀង | ទីប្រឹក្សាសម្ដេចនាយករដ្ឋមន្ត្រី | អនុប្រធាន |
| - ឯកឧត្ដម ឧត្ដមសេនីយ៍ឯក ម៉ៅ ច័ន្ទតារា | អគ្គស្នងការរងនគរបាលជាតិ ក្រសួងមហាផ្ទៃ | សមាជិក |
| - ឯកឧត្ដម ប៉ុល លឹម | អគ្គាធិការរង និងជាប្រធានក្រុមអ្នកច្បាប់ ក្រសួងមហាផ្ទៃ | សមាជិក |
| - ឯកឧត្ដម គ្រាញ់ តូនី | សមាជិកក្រុមប្រឹក្សាអ្នកច្បាប់នៃទីស្ដីការគណៈរដ្ឋមន្ត្រី | សមាជិក |

- ឧត្តមសេនីយ៍ត្រី គៀន ចំនួថរិទ្ធិ ប្រធាននាយកដ្ឋានជនបរទេស ក្រសួងមហាផ្ទៃ សមាជិក
- លោក កែវ ទិសិដ្ឋ អនុប្រធាននាយកដ្ឋានច្បាប់ កុងស៊ុល ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ សមាជិក

**ប្រការ ២** : ក្រុមការងារនេះមានភារកិច្ចពិនិត្យ ពិភាក្សា លើសេចក្តីព្រាងបទដ្ឋាននានា ឬបញ្ហាទាំងឡាយ ដែលពាក់ព័ន្ធនឹងជនភៀសខ្លួន ដើម្បីលើកយោបល់ដាក់ជូនរាជរដ្ឋាភិបាលពិនិត្យ និងសំរេច ។

**ប្រការ ៣** : សមាជិកក្រុមការងារត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធានក្រុមការងារ ។

**ប្រការ ៤** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី និងឯកឧត្តម អស់លោក ដែលមានឈ្មោះក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសំរេចនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ស ខេ

**ចំលងជូន :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
  "ដើម្បីជូនជ្រាប"
- ដូចប្រការ៤ " ដើម្បីអនុវត្ត "
- ឯកសារ-កាលប្បវត្តិ